**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**


**បេឡាជាតិរបបសន្តិសុខសង្គម**
លេខៈ ០២៨ /១៥ ប.ស.ស


# សេចក្តីជូនដំណឹង
## ស្តីពីការផ្ញើលទ្ធផលអង្កេតគ្រោះថ្នាក់ការងារ តាមរយៈទូរស័ព្ទចល័ត

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) មានកិត្តិយសសូមជម្រាបជូនដំណឹងចំពោះគ្រប់សហគ្រាស គ្រឹះស្ថាន កម្មករនិយោជិតទាំងអស់ ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម ឲ្យបានជ្រាបថា ដើម្បីពង្រឹងលើការផ្តល់តាវកាលិក(ផលប្រយោជន៍ផ្សេងៗ) ពី ប.ស.ស ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា ប.ស.ស នឹងផ្ញើលទ្ធផលអង្កេតគ្រោះថ្នាក់ការងារ(ជាគ្រោះថ្នាក់ការងារ ឬមិនមែនគ្រោះថ្នាក់ការងារ)តាមរយៈសារ(SMS) ចូលទូរស័ព្ទចល័តរបស់ជនរងគ្រោះ ឬអ្នកតំណាងសហគ្រាស គ្រឹះស្ថាន។ ក្នុងករណីដែល លោក លោកស្រី ទទួលបានសារដែលបញ្ជាក់ថាគឺជាគ្រោះថ្នាក់ការងារ សូមតំណាងសហគ្រាស គ្រឹះស្ថាន ឬសាមីជនរងគ្រោះថ្នាក់ការងារទាំងអស់ រួសរាន់មកបំពេញសំណុំបែបបទទាមទារតាវកាលិកនៅបេឡាជាតិរបបសន្តិសុខសង្គមឲ្យបានលឿនបំផុត ដើម្បីសាមីជនរងគ្រោះឆាប់ទទួលបានតាវកាលិកផ្សេងៗដែលមានចែងក្នុងច្បាប់ជាធរមាន។

***បញ្ជាក់៖***

ចំពោះលេខទូរស័ព្ទដែល ប.ស.ស ផ្ញើសារទៅកាន់ទូរស័ព្ទចល័តរបស់តំណាងសហគ្រាស គ្រឹះស្ថាន ឬសាមីជនរងគ្រោះ គឺ លោក លោកស្រី មិនអាចទូរស័ព្ទ ឬផ្ញើសារ ត្រលប់មកវិញបានឡើយ។ ចំពោះចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងការផ្ញើសារនេះ លោក លោកស្រី អាចទូរស័ព្ទទំនាក់ទំនាក់មកលេខ (០២៣) ៨៨២-៦២៣ និង (០២៣) ៩៩៨-៤១៧។

បេឡាជាតិរបបសន្តិសុខសង្គម សង្ឃឹមយ៉ាងមុតមាំថា តំណាងសហគ្រាស គ្រឹះស្ថាន និងបងប្អូនកម្មករនិយោជិតជាសាមីជនរងគ្រោះថ្នាក់ការងារទាំងអស់ ចូលរួមសហការ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ ៨ ឆ្នាំ២០១៥

**នាយក**

**អ៊ុក_សមវិទ្យា**